ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំតាក់តែង សេចក្តីព្រាងច្បាប់ស្តីពីអន្តោប្រវេសន៍ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រម នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ៕

## សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំតាក់តែងសេចក្ដីព្រាងច្បាប់ស្ដីពីអន្តោប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្ដម សន្តិបណ្ឌិត អ៊ុក គឹមលេខ | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្ដម ខួន ស៊ីផាន់ | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣.ឯកឧត្ដម ប៊ុន ហុន | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤.ឯកឧត្ដម ប៉ូលី ដា | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៥.ឯកឧត្ដម នាយឧត្ដមសេនីយ៍ នេត សាវឿន | អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៦.ឯកឧត្ដម នាយឧត្ដមសេនីយ៍ សុខ ផល | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ៧.ឯកឧត្ដម នាយឧត្ដមសេនីយ៍ ម៉ៅ ច័ន្ទតារា | អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ៨.ឯកឧត្ដម នាយឧត្ដមសេនីយ៍ ផាង ពៅ | ប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ៩.ឯកឧត្ដម ប៉ែន ពេជ្រសាលី | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការ អយ្យការនិងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ | សមាជិក |
| ១០.ឯកឧត្ដម ណេប សាមុត | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ១១.ឯកឧត្ដម ឥន យឿន | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២.លោក ថូ សំណាង | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការ ច្បាប់ កុងស៊ុល និងព្រំដែន នៃក្រសួងការ បរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣.លោក សរ សិនិរ៉ា | ប្រធាននាយកដ្ឋាននីតិកម្មនិងច្បាប់ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក ./. |

| | | |
|---|---|---|
| ១៤.លោក ប៊ូរ ប៊ុនណារ៉ា | អនុប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងអន្តរជាតិនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥.លោក ស៊ឹម ហុង | អនុប្រធាននាយកដ្ឋានមុខរបរនិងហត្ថពលកម្ម នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦.កញ្ញា គា ម៉ីម៉ី | នាយករងខុទ្ទកាល័យនៃក្រសួងយុត្តិធម៌ | សមាជិក |

**ប្រការ២.-**

ក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអន្តោប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ មានតួនាទី និងភារកិច្ចដូចតទៅៈ

- ដឹកនាំកិច្ចការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអន្តោប្រវេសន៍និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវច្បាប់ស្តីពីអន្តោប្រវេសន៍ជាតិ អន្តរជាតិ និងច្បាប់ពាក់ព័ន្ធ
- ចុះសិក្សាស្ថានភាពជាក់ស្តែងក្នុងប្រទេស និងក្រៅប្រទេសអំពីការងារអន្តោប្រវេសន៍
- រៀបចំប្រជុំ សិក្ខាសាលា និងពិគ្រោះយោបល់ ដើម្បីប្រមូលផ្តុំធាតុចូល
- លើកសំណើសុំគោលការណ៍ណែនាំនិងអនុសាសន៍ដឹកនាំពីរាជរដ្ឋាភិបាល
- ផ្តល់អនុសាសន៍ដល់ក្រុមការងារបច្ចេកទេស
- ធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពនៃការងារ បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ
- បំពេញការងារផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣.-**

ក្រុមការងារអន្តរក្រសួងទទួលបន្ទុករៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអន្តោប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ មានក្រុមការងារបច្ចេកទេសជាជំនួយការ។

**ប្រការ៤.-**

សមាជិកក្រុមការងារអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥.-**

ក្រុមការងារអន្តរក្រសួងនេះមានសិទ្ធិប្រើត្រារបស់ក្រសួងមហាផ្ទៃ និងលើកសំណើសុំថវិកាដំណើរការការងារក្នុងកញ្ចប់ថវិការបស់ក្រសួងមហាផ្ទៃ។៚

**ប្រការ៦.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ